RAC Ratings

របាយការណ៍ត្រួតពិនិត្យការវាយតម្លៃលទ្ធភាពសង
លេខ៖ ០០៧/២៦
ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៦

ក្រុមហ៊ុន តែលកូថេក

ចំណាត់ថ្នាក់ឥណទាន		ព័ត៌មានសញ្ញាបណ្ណ	
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khBB**	ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**
ទស្សនវិស័យ	**ស្ថិរភាព**	ទំហំ	**២០ លានដុល្លារអាមេរិក**
ប្រវត្តិនៃការវាយតម្លៃលទ្ធភាពសង		ចំនួននៃការទូទាត់	**ប្រចាំឆមាស**
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khB**	រយៈពេលឥណប្រតិទាន	**៥ ឆ្នាំ (មិនមានការទូទាត់ប្រាក់ដើមរយៈពេល១.៥ឆ្នាំ)**
ទស្សនវិស័យ	**អវិជ្ជមាន**	ប្រភេទ	**មិនមានទ្រព្យតម្កល់ ប៉ុន្តែមានបុគ្គលធានា**
ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**	អត្រាគូប៉ុង	**SOFR + ២.៥% ក្នុងមួយឆ្នាំ**
កាលបរិច្ឆេទបោះផ្សាយ	**ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣**	បុគ្គលធានា	**Credit Guarantee & Investment Facility (CGIF)**

អ្នកវាយតម្លៃ៖

លោក ស៊ីសុវត្តិ ចក្រការ CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក ជូ ដេវីត
z.david@ratingagencyofcambodia.com.kh
(+៨៥៥) ៨៦ ៨៦៦ ១៩៨

លោក ពឹង ធៀមហេង
p.theamheng@ratingagencyofcambodia.com.kh
(+៨៥៥) ៨៩ ៦២១ ៨៣៣

កញ្ញា រិន មន្នីរ័ត្ន
r.monyroth@ratingagencyofcambodia.com.kh
(+៨៥៥) ៩៦ ៥៩៧ ៩៣៥១

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងរក្សាចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណរបស់ក្រុមហ៊ុន តែលកូថេក («TCT» ឬ «ក្រុមហ៊ុន») នៅ «**khAAA**» (ចំណាត់ថ្នាក់ជាតិ)។ សញ្ញាបណ្ណនេះមានការធានា១០០% ទៅលើទាំងប្រាក់ដើមនិងការប្រាក់ដោយ Credit Guarantee & Investment Facility («CGIF») ជាស្ថាប័នដែលបច្ចុប្បន្ននេះទទួលបានចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន AA ឬ A-1+ (សកល រយៈពេលវែងនិងខ្លី) ដោយ Standard & Poor's («S&P») និង AAA (ចំណាត់ថ្នាក់ជាតិ) ដោយ RAM Ratings (ម៉ាឡេស៊ី) TRIS Ratings (ថៃ) Fitch Ratings Indonesia និង Pefindo Credit Rating Agency (ឥណ្ឌូនេស៊ី)។

យើងដំឡើងចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនរបស់ TCT ពី «**khB**» ទៅ «**khBB**» (ចំណាត់ថ្នាក់ជាតិ) និងទស្សនវិស័យ ពី «**អវិជ្ជមាន**» មក «**ស្ថិរភាព**» វិញ។ ការដំឡើងនេះត្រូវបានជំរុញដោយលទ្ធផលល្អប្រសើរប្រចាំឆ្នាំរបស់ក្រុមហ៊ុនក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ ២០២៤ និង ២០២៥ ដោយផ្អែកទៅលើកំណើនចំណូលនិងប្រាក់ចំណេញ។ តាមទស្សនៈរបស់យើង វាជាលទ្ធផលដែលទទួលបានបន្ទាប់ពីមានការពង្រីកខ្សែកាបក្រោមបាតសមុទ្រ និងវិសាលភាព គ្របដណ្តប់កាន់តែទូលំទូលាយ ក៏ដូចជាការភ្លាយជាច្រកដ៏សំខាន់មួយសម្រាប់ចរាចរណ៍អ៊ីនធឺណិតរបស់ប្រទេសកម្ពុជា។ បើប្រៀបធៀបទៅឆ្នាំហិរញ្ញវត្ថុ ២០២៣ ប្រាក់ចំណូលមានការកើនឡើងខ្លាំងដូចនឹងផែនការយុទ្ធសាស្ត្រដែលក្រុមហ៊ុនបានគ្រោងទុក ខណៈដែលអត្រាប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំវិញបានកើនឡើងច្រើនជាងប្រាំដងទៅទៀត។

លើសពីនេះ សូចនាករវិជ្ជមានដូចជាការថយចុះនៃអនុបាតកម្រិតបំណុលនិងលំហូរសាច់ប្រាក់ល្អ បានបញ្ជាក់បន្ថែមពីភាពធន់នៃហិរញ្ញវត្ថុក្រុមហ៊ុន ទោះបីជាមានការសងប្រាក់ដើមដំណាក់កាលដំបូងនាចុងឆ្នាំ២០២៥ ក៏ដោយ។ ផែនការពង្រីកយុទ្ធសាស្ត្រក៏ដូចជាការត្រៀមខ្លួនជាស្រេចសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ 5G របស់ក្រុមហ៊ុននឹងក្លាយជាកាតាលីករដ៏សំខាន់ ក្នុងការកាន់កាប់ចំណែកទីផ្សារ និងបង្កើនប្រាក់ចំណូលប្រកបដោយចីរភាព។

យើងជឿជាក់ថា TCT អាចនឹងពង្រីកវិសាលភាពយូរអង្វែងប្រកបដោយចីរភាព ដែលត្រូវបានគាំទ្រដោយលទ្ធផលប្រតិបត្តិការនាពេលបច្ចុប្បន្នរបស់ខ្លួន និងក្នុងនាមជាក្រុមហ៊ុនផ្តត់ផ្តង់សេវាហេដ្ឋារចនាសម្ព័ន្ធទូគេមនាគមន៍និងសេវាកម្មពាក់ព័ន្ធឈានមុខគេមួយនៅព្រះរាជាណាចក្រកម្ពុជា។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

ទស្សនវិស័យ

បន្ទាប់ពីបានបោះផ្សាយសញ្ញាបណ្ណ កម្រិតបំណុលរបស់ TCT បានកើនឡើងដល់កម្រិតកំពូលនៅដំណាច់ឆ្នាំ២០២៤។ នៅឆ្នាំហិរញ្ញវត្ថុ២០២៥ អនុបាតបំណុលធៀបនឹងមូលធនមានភាពប្រសើរឡើងវិញបន្តិចបន្តួច បន្ទាប់ពីមានការសងប្រាក់ដើមខ្លះទៅលើសញ្ញាបណ្ណបោះផ្សាយលក់ជាឯកជននិងសាធារណៈទាំងពីរ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺការប្រើប្រាស់ប្រាក់ចំណូលបានពីការបោះផ្សាយសញ្ញាបណ្ណដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយមូលធន បានជំរុញឱ្យប្រាក់ចំណូលក្រុមហ៊ុនកើនឡើងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ និន្នាការកន្លងមកបូករួមបញ្ចូលជាមួយនឹងយុទ្ធសាស្ត្រចំណាយមូលធន និងផែនការពង្រីកវិសាលភាពរបស់គណៈគ្រប់គ្រង អាចនឹងធានាបាននូវកំណើនផលចំណេញជាលំដាប់នៅថ្ងៃអនាគត។ ជាលទ្ធផល យើងដំឡើងទស្សនវិស័យពី «**អវិជ្ជមាន**» មក «**ស្ថិរភាព**» វិញ។

កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ក្នុងករណីដែលអាចប្រសើរឡើង ប្រសិនបើយើងពិនិត្យឃើញថាមានកំណើនប្រាក់ចំណេញជាបន្តបន្ទាប់ ការកើនឡើងនៃអនុបាតលទ្ធភាពទូទាត់ការប្រាក់ ការថយចុះបន្តែមនៃអនុបាតបំណុលធៀបនឹងមូលធន ការរក្សាលំហូរសាច់ប្រាក់បានល្អ និងការគ្រប់គ្រងហានិភ័យអាជីវកម្មជាក់ស្តែង នោះយើងនឹងធ្វើការដំឡើងចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន។

ផ្ទុយទៅវិញ ក្នុងករណីដែលមានការកើនឡើងយ៉ាងគំហុកនៃកម្រិតហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អាចបណ្តាលឱ្យយើងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនបាន។ ចំណែកឯ ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណវិញ ដោយសារតែវាអាស្រ័យទៅនឹងចំណាត់ថ្នាក់ជាសកលរបស់ CGIF (AA ដោយ S&P) នោះយើងអាចនឹងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ ឥណទានសញ្ញាបណ្ណ ប្រសិនបើចំណាត់ថ្នាក់ជាសកលរបស់ CGIF ត្រូវបានបន្ទាប។

បញ្ហាដែលត្រូវត្រួតពិនិត្យ

និន្នាការកំណើនប្រាក់ចំណូលរបស់ TCT ប្រាក់ចំណេញ ស្ថានភាពបំណុល ចីរភាពនៃលំហូរសាច់ប្រាក់ប្រតិបត្តិការ កិច្ចព្រមព្រៀងឥណទានគ្រុបជាមួយ Ezecom បូករួមជាមួយលទ្ធផលនៃការបង្កើតខ្សែបណ្តាញថ្មី រួមទាំងការវិនិយោគលើការរៀបចំប្រព័ន្ធ Backhaul សម្រាប់បច្ចេកវិទ្យា5G ជាចំណុចសំខាន់ដែលត្រូវត្រួតពិនិត្យ និងតាមដានផងដែរ។

សេចក្តីសង្ខេបអំពី ក្រុមហ៊ុន តែលកូថេក

ទិដ្ឋភាពទូទៅ

ឆ្នាំហិរញ្ញវត្ថុ២០២៤ ជាឆ្នាំល្អមួយសម្រាប់កំណើនប្រាក់ចំណូល និងប្រាក់ចំណេញប្រចាំឆ្នាំរបស់ TCT ជំរុញដោយការហក់ឡើងនៃប្រភពចំណូលស្នូលពីរ រួមមាន International Private Leased Circuit (IPLC) ដែលបានកើនឡើង ៨៨,៣% និង Fiber-optic wholesale ដែលបានកើនឡើង ១៨,៧% ធៀបនឹងឆ្នាំមុន។ សម្រាប់ចក្ខុវិស័យនាពេលអនាគត ADB និង IMF បានព្យាករណ៍ថាប្រទេសកម្ពុជានឹងមានកំណើនសេដ្ឋកិច្ចចន្លោះពី ៤,០% ទៅ ៥,០% សម្រាប់ឆ្នាំ២០២៦នេះ ស្របជាមួយនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល (២០២១-២០៣៥) រំពឹងថានឹងជំរុញតម្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទូរគមនាគមន៍ដែលផ្តល់ដោយ TCT។ ការព្យាករណ៍នេះរួមជាមួយភាពល្អប្រសើរនៃលទ្ធផលសម្រេចផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន បង្ហាញឱ្យឃើញពីឱកាសរីកចម្រើនបន្ថែមទៀត។

ការប្រតិបត្តិ

សម្រាប់ពីរឆ្នាំចុងក្រោយនេះ TCT ទទួលបានសមិទ្ធផលដ៏ប្រសើរ គឺចំណូលបានកើនដល់ ៣០,១លានដុល្លារអាមេរិក នៅឆ្នាំ២០២៤ និង ៣១,៨លានដុល្លារអាមេរិក នៅឆ្នាំ២០២៥ ដែលជាតួលេខខ្ពស់បំផុតតាំងពីឆ្នាំ២០១៩មក។ ប្រាក់ចំណូលរបស់ TCT បានកើនឡើងធៀបនឹងឆ្នាំមុន ៣៥,៦% ក្នុងឆ្នាំ២០២៤ និង ៥,៨%ក្នុងឆ្នាំ២០២៥ធៀបនឹងឆ្នាំមុន ដែលនេះបញ្ជាក់បន្ថែមបានថាក្រុមហ៊ុនកំពុងស្ថិតនៅក្នុងនិន្នាការនៃកំណើនប្រាក់ចំណូលនិងប្រាក់ចំណេញ។ នៅក្នុងឆ្នាំហិរញ្ញវត្ថុ២០២៤ ប្រាក់ចំណេញពីប្រតិបត្តិការមានការកើនឡើងលើសបីដង ដោយសារថ្លៃដើមនៃទំនិញដែលបានលក់ចេញ (COGS) និងចំណាយប្រតិបត្តិការធៀបនឹងចំណូលមានការធ្លាក់ចុះជាងមុន។ នេះបង្ហាញឱ្យឃើញថា ក្រុមហ៊ុនកំពុងមានប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាព និងកាន់តែប្រសើរឡើង។ ជាមួយគ្នាផងដែរ ប្រាក់ចំណេញប្រចាំឆ្នាបានកើនឡើង ៥៨៦,៥% ធៀបនឹងឆ្នាំមុន។ ក្រៅពីទិដ្ឋភាពនៃលទ្ធភាពប្រាក់ចំណេញ គឺមានសញ្ញាវិជ្ជមានផ្សេងទៀតដូចជា ការថយចុះនៃអនុបាតកម្រិតបំណុល និងសាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការមានភាពល្អប្រសើរ។ ចំណែកឯឆ្នាំហិរញ្ញវត្ថុ២០២៥វិញ TCT មានការកើនឡើងបន្តិចបន្តួចនូវ មូលនិធិពីប្រតិបត្តិការ (FFO) និង លំហូរសាច់ប្រាក់ទំនេរពីប្រតិបត្តិការ (FOCF)។

សម្គាល់៖ ក្នុងអំឡុងពេលនៃការវាយតម្លៃចំណាត់ថ្នាក់ឥណទានដំបូង គឺមានកំហុសក្នុងការគណនា «បរិមាណបំណុល»។ នៅក្នុងរបាយការណ៍ត្រួតពិនិត្យការវាយតម្លៃលទ្ធភាពសងនេះ កំហុសត្រូវបានកែតម្រូវរួចរាល់។ ការដំឡើងចំណាត់ថ្នាក់ឥណទានក្រុមហ៊ុននិងទស្សនវិស័យនេះ មិនមែនដោយសារតែការកែតម្រូវកំហុសប៉ុណ្ណោះទេ ប៉ុន្តែយើងសង្កេតឃើញថាក្រុមហ៊ុនមានភាពរីកចម្រើនក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះដែរ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

របាយការណ៍ហិរញ្ញវត្ថុសង្ខេប

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ដុល្លារអាមេរិក	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដុល្លារអាមេរិក
របាយការណ៍ចំណេញ/ខាត					
ចំណូល	១៦.៥០៥.១២២	២១.៩៤៣.៩៨០	២២.១៩០.៥៧១	៣០.១០១.១៧៤	៣១.៨៤០.៣៣៣
ចំណេញដុល	១.៣០៥.០៤៥	៤.៦១៥.៧៣០	៣.៤៩៩.៥០១	៧.៥៦៦.៦៤១	៦.៨៥៣.០២៧
ចំណេញពីប្រតិបត្តិការ	(២៨២.៣០៥)	៣.៧៧៤.៩២០	១.៦៣២.៩៧៧	៥.៤០៧.៨២០	៤.៨៣១.៤៦៦
ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ	(១.៧៥៤.៨៦៣)	២.៥៦៤.៥១៤	៦៦៨.៣១១	៣.៤១៥.៤៥១	៣.១២២.២៧៤
ប្រាក់ចំណេញប្រចាំឆ្នាំ	**(៤២៥.៧៣៦)**	**២.០៤៨.៥៧៥**	**៤៩១.២៧៥**	**៣.៣៧២.៥៨២**	**២.៧៤១.១៩៤**
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
ទ្រព្យសកម្ម					
សាច់ប្រាក់ និងសមតុល្យធនាគារ	៣.៥៥៥.៩៨២	១០.៩៤៧.៦២៤	១២.២៤៧.៨៧២	៨.៦៩០.៦០២	៥.៤៧០.០៧៦
ប្រាក់បញ្ញើមានកាលកំណត់	៦.០០០.០០០	១.៥៦៤.៥៧០	៥.១០៤.៣៨៤	១៣.៥០៧.៧៦៧	១៦.៣១៨.៣៦៤
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	១៣.៥៤៥.០៥៧	៨.០៧៩.១៤៩	១.៨០៧.២៦៨	៦.៧៩១.៩៩៦	៥.៥៥៥.៦៤៨
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**២៣.២៥៤.៨១៨**	**២០.៧២៣.៤៣៨**	**១៩.៤៥៨.៥៥១**	**២៩.២៨៣.៤៤៦**	**២៧.៥៣០.៨២៦**
ទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខារ	៣៣.៨៧៣.៨៣៨	៤០.២៩៥.០៧៦	៤១.៩៦៥.០៤៨	៤៤.៣៣៦.៧៩២	៤២.៦២៥.២៥៨
ទ្រព្យសកម្មរយៈពេលវែងសរុប	**៣៨.៥១១.៨៧៥**	**៤៥.២៩៤.៧២៨**	**៤៣.២២៨.០០១**	**៤៦.០៥៦.៤២០**	**៤៣.៩៨៣.៤៤៦**
ទ្រព្យសកម្មសរុប	**៦១.៧៦៦.២៩៣**	**៦៦.០១៨.១៦៦**	**៦២.៦៨៦.៥៥២**	**៧៥.៣៣៩.៨៦៦**	**៧១.៥១៤.២៧២**
បំណុលនិងមូលធន					
គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ	៧.៤២៩.៨២១	១៣.៧២៦.២៦៩	៦.៦០៧.០៥២	៥.៤៩០.៣៥៣	៣.២៨៩.៥៩៣
ចំនួនត្រូវសងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	១.២៧៣.៣៨៤	១.៧៩៤.៨៣៦	១.៣៨៥.៥៤៦	២.៦០៧.០៤១	៤.១៨៥.៦៥៦
មូលបត្របំណុល	៤.០៧១.៦៩៨	៤.០២៤.៣៦៧	៣.៥២៨.៤៧៥	៥.៦៦៥.៤១៦	៧.៧៦០.៩៧១
បំណុលរយៈពេលខ្លីសរុប	**១៣.៧១៩.១៤៤**	**២០.០៣៧.៧៩៧**	**១២.១៨៩.៧៦៣**	**១៤.៤៣៩.៥៦៧**	**១៥.៦៤៥.៤៣៣**
មូលបត្របំណុល	១៥.២៦៦.៧៧០	១១.៤៥៩.៩១៩	១៤.៣៨២.៥២៩	២១.៤៨៥.៨២០	១៣.៦៦៩.៥៨៥
បំណុលរយៈពេលវែងសរុប	**១៨.៩៩៤.១៤២**	**១៤.៨៧៨.៧៨៧**	**១៨.៩១៦.៧០១**	**២៥.៩៤៧.៦២៩**	**១៨.១៧៤.៩៧៥**
បំណុលសរុប	**៣២.៧១៣.២៨៦**	**៣៤.៩១៦.៥៨៤**	**៣១.១០៦.៤៦៤**	**៤០.៣៨៧.១៩៦**	**៣៣.៨២០.៤០៨**
ដើមទុន	១១.៨៥៦.៦៨៨	១១.៨៥៦.៦៨៨	១១.៨៥៦.៦៨៨	១១.៨៥៦.៦៨៨	១១.៨៥៦.៦៨៨
បុព្វលាភភាគហ៊ុន	១៧.១៩៦.៣១៩	១៩.២៤៤.៨៩៤	១៩.៧២៣.៤០០	២៣.០៩៥.៩៨២	២៥.៨៣៧.១៧៦
មូលធនសរុប	**២៩.០៥៣.០០៧**	**៣១.១០១.៥៨២**	**៣១.៥៨០.០៨៨**	**៣៤.៩៥២.៦៧០**	**៣៧.៦៩៣.៨៦៤**
បំណុលនិងមូលធនសរុប	**៦១.៧៦៦.២៩៣**	**៦៦.០១៨.១៦៦**	**៦២.៦៨៦.៥៥២**	**៧៥.៣៣៩.៨៦៦**	**៧១.៥១៤.២៧២**
របាយការណ៍លំហូរសាច់ប្រាក់					
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ	១១.៦៤១.០០៦	១១.៤១០.០១៤	៤.៩១៣.៦១៣	៣.១៤៧.៣២០	៩.៣៦១.៣០៣
សាច់ប្រាក់សុទ្ធបានពីសកម្មភាពវិនិយោគ	(១៥.២៨៥.៨៨៥)	៧៨០.៨៣៧	(៦.៥១៩.០១៧)	(២០.៨៣១.៩១១)	(៦.៧៤៣.៩២៩)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន	៧.០៦៣.៨៧៨	(៤.០៨៩.២០៩)	៧.៣០០.០៣៦	៩.០២២.៩៣៧	(៥.៨៣៧.៩០០)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងឆ្នាំ	**៣.៤១៨.៩៩៩**	**៨.១០១.៦៤២**	**៥.៦៩៤.៦៣២**	**(៨.៦៦១.៦៥៤)**	**(៣.២២០.៥២៦)**
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមឆ្នាំ	១៣៦.៩៨៣	៣.៥៥៥.៩៨២	១១.៦៥៧.៦២៤	១៧.៣៥២.២៥៦	៨.៦៩០.៦០២
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងឆ្នាំ	**៣.៥៥៥.៩៨២**	**១១.៦៥៧.៦២៤**	**១៧.៣៥២.២៥៦**	**៨.៦៩០.៦០២**	**៥.៤៧០.០៧៦**

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់វាយតម្លៃឥណទាន (ចំណាត់ថ្នាក់ជាតិ)			
ចំណាត់ថ្នាក់ជាតិ	**និយមន័យ**	**ពិន្ទុ**	
khAAA	សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	១	ហានិភ័យទាបណាស់
khAA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	២	
khA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៣	ហានិភ័យទាប
khBBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៤	
khBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៥	ហានិភ័យមធ្យម
khB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៦	
khCCC	សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល	៧	ហានិភ័យខ្ពស់
khCC	សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៨	
khC	ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៩	ហានិភ័យខ្ពស់ណាស់
khD	មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់	១០	

កំណត់សម្គាល់៖

ព័ត៌មាន និងទិន្នន័យស្ថិតនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវឬស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតជីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះបង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវឬស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលរយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website